ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

សាលាដំបូង
ខេត្តបន្ទាយមានជ័យ

សំណុំរឿងព្រហ្មទណ្ឌលេខ : ១១៥៦
ចុះថ្ងៃទី១២ ខែតុលា ឆ្នាំ២០២០
ជំនុំជម្រះថ្ងៃទី : ១៧-កុម្ភៈ-២០២១
សាលក្រមលេខ : ១៤ "ឈ"/១២៣
ចុះថ្ងៃទី១៨ ខែមីនា ឆ្នាំ២០២១

# សាលក្រមព្រហ្មទណ្ឌ
# តាងនាមប្រជារាស្ត្រខ្មែរ
# សាលាដំបូងខេត្តបន្ទាយមានជ័យ

បានបើកសវនាការជាអសាធារណៈ នៅសាលាដំបូងខេត្តបន្ទាយមានជ័យ នាថ្ងៃទី១៧ ខែកុម្ភៈ ឆ្នាំ២០២១ វេលាម៉ោង បីរសៀល។

បានប្រកាសសាលក្រមជាអសាធារណៈ នាថ្ងៃទី១៨ ខែមីនា ឆ្នាំ២០២១ វេលាម៉ោង បីរសៀល។

## សមាសភាពក្រុមប្រឹក្សាជំនុំជម្រះ

- លោក [redacted] ជាប្រធានក្រុមប្រឹក្សាជំនុំជម្រះ
- លោក [redacted] ជាចៅក្រមប្រឹក្សា
- លោក [redacted] ជាចៅក្រមប្រឹក្សា

## តំណាងអយ្យការ

- លោកស្រី [redacted] ជាព្រះរាជអាជ្ញារង

## ក្រឡាបញ្ជីសវនាការ

- កញ្ញា [redacted] ជាក្រឡាបញ្ជី

## មេធាវី

- លោក [redacted] ជាមេធាវីការពារសិទ្ធិឱ្យជនជាប់ចោទ ឈ្មោះ [redacted] ជាវីត , [redacted] លីដា
- កញ្ញា [redacted] ជាមេធាវីការពារសិទ្ធិឱ្យជនជាប់ចោទ ឈ្មោះ [redacted] ជាវីត , [redacted] លីដា

## ដើម្បីជំនុំជម្រះ

លើសំណុំរឿងព្រហ្មទណ្ឌលេខ ១១៥៦ ចុះថ្ងៃទី១២ ខែតុលា ឆ្នាំ២០២០ ដែលមានជនជាប់ចោទ ដូចខាងក្រោម ៖



Scanned with CamScanner

១.ឈ្មោះ [redacted] **ដារីត** ភេទប្រុស កើតថ្ងៃទី០៨.០៩.២០០៣ សញ្ជាតិខ្មែរ អនីតិជន មុខរបរ កម្មករ សាសនាគ្រិស្ត កម្រិតវប្បធម៌ថ្នាក់ទី១០ថ្មី ទីកន្លែងកំណើតភូ[redacted] ខេត្តបន្ទាយមានជ័យ អាសយដ្ឋានមុនពេលឃុំខ្លួនភូ[redacted]ខេត្តបន្ទាយមានជ័យ ឪពុកឈ្មោះ [redacted]គិន (រស់) ម្តាយឈ្មោះ [redacted] សាវរ៉េត (រស់) នៅលីវ ទោសពីមុន **ធ្លាប់ជាប់មណ្ឌលកែប្រែជីវិតថ្មី ភ្នំបាក់ចំនួន ០៣ ខែ**។ (ក្នុងឃុំ)

(ដីកាបង្គាប់ឱ្យឃុំខ្លួនលេខ : ៦២៧ ព្រ.ទ៣"ឈ"/២០ ចុះថ្ងៃទី១៣ ខែតុលា ឆ្នាំ២០២០)

**២.ឈ្មោះ** [redacted] **លីដា** ភេទស្រី កើតឆ្នាំ២០០៤ សញ្ជាតិខ្មែរ អនីតិជន មុខរបរ នៅផ្ទះ សាសនាព្រះពុទ្ធ កម្រិតវប្បធម៌ថ្នាក់ទី១១ថ្មី ទីកន្លែងកំណើតភូមិ[redacted] ខេត្តបន្ទាយមានជ័យ អាសយដ្ឋានមុនពេលឃុំខ្លួន[redacted] ខេត្តបន្ទាយមានជ័យ ឪពុកឈ្មោះ [redacted] វ៉ាន់ (រស់) ម្តាយឈ្មោះ [redacted] ឆាត (រស់) នៅលីវ ទោសពីមុន **គ្មាន**។ (ក្នុងឃុំ)

(ដីកាបង្គាប់ឱ្យឃុំខ្លួនលេខ : ៦២៨ ព្រ.ទ៣"ឈ"/២០ ចុះថ្ងៃទី១៣ ខែតុលា ឆ្នាំ២០២០)

ជាប់ចោទពីបទ **"ជួញដូរ និងប្រើប្រាស់ដោយខុសច្បាប់នូវសារធាតុញៀន"** ប្រព្រឹត្តនៅភូមិភ្នំតូចត្បូង ឃុំភ្នំតូច ស្រុកមង្គលបូរី ខេត្តបន្ទាយមានជ័យ កាលពីថ្ងៃទី១០ ខែតុលា ឆ្នាំ២០២០ តាមបញ្ញត្តិមាត្រា **៤០ កថាខណ្ឌ៤** និងមាត្រា **៤៥** នៃច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន។

## <u>**អង្គហេតុកើតឡើងមានដូចតទៅ**</u> :

កាលពីថ្ងៃទី១០ ខែតុលា ឆ្នាំ២០២០ វេលាម៉ោង ១៧:៣០នាទី ឈ្មោះ [redacted] **ដារីត** ភេទប្រុស និងឈ្មោះ [redacted] **លីដា** ភេទស្រី បានយកគ្រឿងញៀនប្រភេទម៉ាទឹកកក ទៅលក់ឱ្យគេចំនួន ០២កញ្ចប់ ពេលធ្វើដំណើរដល់ចំណុចភូមិគោកព្នៅ ឃុំបន្ទាយនាង ស្រុកមង្គលបូរី ខេត្តបន្ទាយមានជ័យ ក៏ត្រូវកម្លាំងអធិការដ្ឋាននគរបាលស្រុកមង្គលបូរី ចេញល្បាតក្នុងភូមិសាស្ត្រប្រទះឃើញ ក៏ឃាត់ខ្លួនជនសង្ស័យទាំងពីរនាក់ និងដកហូតវត្ថុតាងមាន: ម្សៅក្រាមពណ៌សថ្លាចំនួន ០២ កញ្ចប់ ។ ក្រោយពីសួរចម្លើយឈ្មោះ [redacted] **ដារីត** និងឈ្មោះ [redacted] **លីដា** ឆ្លើយថា: ខ្លួនពិតជាចេះប្រើប្រាស់គ្រឿងញៀនប្រាកដមែន នៅថ្ងៃទី១០ ខែតុលា ឆ្នាំ២០២០ ឈ្មោះ [redacted] ភេទប្រុស បានឱ្យគ្រឿងញៀនម៉ាទឹកកកមកខ្លួនចំនួន ០២ កញ្ចប់ ដើម្បីយកទៅលក់ឱ្យគេប្រាកដមែន។

បានឃើញ : ដីកាសន្និដ្ឋានស្ថាពរលេខ : ១១៧៩ អយក ចុះថ្ងៃទី២៥ ខែធ្នូ ឆ្នាំ២០២០។

បានឃើញ : ដីកាដំណោះស្រាយលេខ : ៥៤២៦ ពស.ព្រស(ឈ)/២០ ចុះថ្ងៃទី២៥ ខែធ្នូ ឆ្នាំ២០២០។

បានឃើញ : ដីកាចាត់តាំងក្រុមប្រឹក្សាចៅក្រមជំនុំជម្រះលេខ : ៥២ ពស.ព្រជ"ក"/២១ ចុះថ្ងៃទី២០ ខែមករា ឆ្នាំ២០២១។

បានឃើញ : ឯកសារនានាក្នុងសំណុំរឿងព្រហ្មទណ្ឌលេខ : ១១៥៦ ចុះថ្ងៃទី១២ ខែតុលា ឆ្នាំ២០២០ ។

បានឃើញ : ការផ្តល់ និងការជូនដំណឹងអំពីកាលបរិច្ឆេទនៃសវនាការ ដែលធ្វើឡើងអនុលោមតាមបញ្ញត្តិមាត្រា **២៩២** និងមាត្រាបន្តបន្ទាប់នៃក្រមនីតិវិធីព្រហ្មទណ្ឌ ។

## <u>**នាពេលសវនាការ**</u> :

- ក្រោយពីបាន ស្តាប់ចម្លើយរបស់ជនជាប់ចោទឈ្មោះ [redacted] **ដារីត**
- ក្រោយពីបាន ស្តាប់ចម្លើយរបស់ជនជាប់ចោទឈ្មោះ [redacted] **លីដា**
- ក្រោយពីបាន ពិនិត្យឯកសារ និង ភស្តុតាងនានាដែលពាក់ព័ន្ធនៅក្នុងសំណុំរឿងនេះ
- ក្រោយពីបាន ស្តាប់សេចក្តីសន្និដ្ឋានប្តឹងសុំរបស់តំណាងអយ្យការ



Scanned with CamScanner

- ក្រោយពីបាន ស្តាប់សេចក្តីសន្និដ្ឋានការពាររបស់មេធាវីការពារសិទ្ធិឱ្យជនជាប់ចោទ
- ក្រោយពីបាន ស្តាប់សម្តីចុងក្រោយរបស់ជនជាប់ចោទទាំងពីរនាក់
- ក្រោយពីបាន ពិនិត្យ ពិភាក្សា និងពិចារណា ត្រឹមត្រូវតាមច្បាប់ហើយ

## <u>**សាលាដំបូងខេត្ត បន្ទាយមានជ័យ**</u>

## <u>**យល់ឃើញថា**</u> :

១.តាមរយៈដីកាដំណោះស្រាយ លេខ : ៥៤២៦ ពស.ព្រស(ឈ)/២០ ចុះថ្ងៃទី២៥ ខែធ្នូ ឆ្នាំ២០២០ របស់ចៅក្រមស៊ើបសួរ បានសម្រេចបញ្ជូនជនជាប់ចោទឈ្មោះ [redacted] **ដាទីត** ភេទប្រុស កើតថ្ងៃទី០៨.០៩.២០០៣ និងឈ្មោះ [redacted] **លីដា** ភេទស្រី កើតឆ្នាំ២០០៤ មកធ្វើការជំនុំជម្រះពីបទ "**ជួញដូរ និងប្រើប្រាស់ដោយខុសច្បាប់នូវសារធាតុញៀន**" ប្រព្រឹត្តនៅភូមិភ្នំតូចត្បូង ឃុំភ្នំតូច ស្រុកមង្គលបូរី ខេត្តបន្ទាយមានជ័យ កាលពីថ្ងៃទី១០ ខែតុលា ឆ្នាំ២០២០ តាមបញ្ញត្តិមាត្រា **៤០ កថាខណ្ឌ៤** និងមាត្រា **៤៥** នៃច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន។

២.តាមចម្លើយរបស់ជនជាប់ចោទឈ្មោះ [redacted] **ដាទីត** បានឆ្លើយនាពេលសវនាការថា : ខ្លួនពិតជាចេះប្រើប្រាស់គ្រឿងញៀនប្រាកដមែន។ នៅថ្ងៃទី១០ ខែតុលា ឆ្នាំ២០២០ ឈ្មោះ **ថាត់** បានឱ្យគ្រឿងញៀនម៉ាទឹកកកមកខ្លួនប្រើប្រាស់ រួចហើយឈ្មោះ **ថាត់** បានឱ្យគ្រឿងញៀនម៉ាទឹកកកចំនួន ០២កញ្ចប់តូច លក់ក្នុងតម្លៃ ២០.០០០(ពីរម៉ឺន)រៀល ដើម្បីឱ្យខ្លួនយកទៅលក់ឱ្យគេនៅផ្លូវបន្ទាយនាង។ លុះពេលខ្លួនយកគ្រឿងញៀនទៅលក់ឱ្យគេ ក៏ត្រូវសមត្ថកិច្ចឃាត់ខ្លួន និងឆែកឆេរខ្លួនរកឃើញគ្រឿងញៀនចំនួន ០២កញ្ចប់តូចតែម្តង នៅក្នុងរឿងនេះខ្លួនបានដឹងកំហុសហើយ ខ្លួនសំណូមពរសុំឱ្យតុលាការមេត្តាបន្ធូរបន្ថយទោសដល់រូបខ្លួនផង។

៣.តាមចម្លើយរបស់ជនជាប់ចោទឈ្មោះ [redacted] **លីដា** បានឆ្លើយនាពេលសវនាការថា : កាលពីថ្ងៃទី១០ ខែតុលា ឆ្នាំ២០២០ ឈ្មោះ **ថាត់** បានឱ្យគ្រឿងញៀនម៉ាទឹកកកមកខ្លួនប្រើប្រាស់ ហើយបានឱ្យគ្រឿងញៀនប្រភេទម៉ាទឹកកកចំនួន ០២កញ្ចប់តូច ដើម្បីឱ្យខ្លួនយកទៅលក់ឱ្យគេនៅផ្លូវបន្ទាយនាង។ លុះពេលខ្លួនយកគ្រឿងញៀនទៅលក់ឱ្យគេ ក៏ត្រូវសមត្ថកិច្ចឃាត់ខ្លួន និងឆែកឆេរខ្លួនរកឃើញគ្រឿងញៀនចំនួន ០២កញ្ចប់តូចតែម្តង នៅក្នុងរឿងនេះខ្លួនបានដឹងកំហុសហើយ ខ្លួនសំណូមពរសុំឱ្យតុលាការមេត្តាបន្ធូរបន្ថយទោសដល់រូបខ្លួនផង។

៤.តាមរយៈចម្លើយរបស់ជនជាប់ចោទទាំងពីរនាក់ មានលក្ខណៈច្បាស់លាស់ស៊ីសង្វាក់ទៅនឹងរបាយការណ៍របស់មន្ត្រីនគរបាលយុត្តិធម៌ និងភស្តុតាងផ្សេងៗដែលមាននៅក្នុងសំណុំរឿង អាចធ្វើឱ្យតុលាការជឿជាក់បានថា ពិតជាមានករណីនៃអង្គហេតុ "**ជួញដូរ និងប្រើប្រាស់ដោយខុសច្បាប់នូវសារធាតុញៀន**" ដែលបង្កឡើងដោយជនជាប់ចោទឈ្មោះ [redacted] **ដាទីត** និងឈ្មោះ [redacted] **លីដា** ប្រាកដមែន។

៥.ផ្អែកតាមសកម្មភាព និងចម្លើយសារភាពរបស់ជនជាប់ចោទឈ្មោះ [redacted] **ដាទីត** និងឈ្មោះ [redacted] **លីដា** បានទិញគ្រឿងញៀនយកមកលក់បន្តដើម្បីបានប្រាក់ចំណេញ និងចំណេញបានថ្នាំញៀនប្រើប្រាស់ ដែលនេះជាអំពើ "**ជួញដូរ និងប្រើប្រាស់ដោយខុសច្បាប់នូវសារធាតុញៀន**" ដោយច្បាប់តម្រូវឱ្យផ្តន្ទាទោសតាមបញ្ញត្តិមាត្រា **៤០ កថាខណ្ឌ៤ និងមាត្រា ៤៥** នៃច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន។

៦.តំណាងអយ្យការបានធ្វើសេចក្តីសន្និដ្ឋានថា : តាមចម្លើយរបស់ជនជាប់ចោទឈ្មោះ [redacted] **ដាទីត** និងឈ្មោះ [redacted] **លីដា** ព្រមទាំងភស្តុតាងផ្សេងៗដែលមាននៅក្នុងសំណុំរឿង សរបញ្ជាក់ឱ្យឃើញថា ពិតជាមានករណី "**ជួញដូរ និងប្រើប្រាស់ដោយខុសច្បាប់នូវសារធាតុញៀន**" ប្រព្រឹត្តដោយជនជាប់ចោទឈ្មោះ

[redacted] **ជាទីត** និងឈ្មោះ [redacted] **លីដា** ប្រាកដមែន។ ដូចនេះប្តឹងសុំឱ្យលោកចៅក្រមជំនុំជម្រះសម្រេចផ្តន្ទាទោសជនទាំងនេះទៅតាមច្បាប់ ជាការសន្និដ្ឋានគប្បីពិចារណា។

**៧.**លោក [redacted] មេធាវីការពារសិទ្ធិឱ្យជនជាប់ចោទ បានធ្វើសេចក្តីសន្និដ្ឋានថា កូនក្តីរបស់ខ្លួនឈ្មោះ [redacted] **ជាទីត** និងឈ្មោះ [redacted] **លីដា** បានសារភាពភ្ញាក់រលឹកនូវកំហុសរបស់ខ្លួន ខ្លួនសំណូមសុំឱ្យលោកប្រធានក្រុមប្រឹក្សាមេត្តាបន្ធូរបន្ថយទោសដល់កូនក្តីរបស់ខ្លួនផង គប្បីតុលាការនឹងលើកយកមកពិនិត្យ និងពិចារណាតាមផ្លូវច្បាប់ ។

៨.មានពិរុទ្ធភាពគ្រប់គ្រាន់លើឈ្មោះ [redacted] **ជាទីត** ភេទប្រុស កើតថ្ងៃទី០៨.០៩.២០០៣ និងឈ្មោះ [redacted] **លីដា** ភេទស្រី កើតឆ្នាំ២០០៤ ពីបទ **"ជួញដូរ និងប្រើប្រាស់ដោយខុសច្បាប់នូវសារធាតុញៀន"** ប្រព្រឹត្តនៅភូមិភ្នំតូចត្បូង ឃុំភ្នំតូច ស្រុកមង្គលបូរី ខេត្តបន្ទាយមានជ័យ កាលពីថ្ងៃទី១០ ខែតុលា ឆ្នាំ២០២០ តាមបញ្ញត្តិមាត្រា **៤០ កថាខណ្ឌ៤** និងមាត្រា **៤៥** នៃច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន។

៩.ជនជាប់ចោទឈ្មោះ [redacted] **ជាទីត** និងឈ្មោះ [redacted] **លីដា** សុទ្ធតែជាអនីតិជន មានលក្ខណៈសម្បត្តិគ្រប់គ្រាន់ក្នុងការទទួលខុសត្រូវលើអំពើប្រព្រឹត្តរបស់ខ្លួន ហើយអំពើនេះបានធ្វើអោយប៉ះពាល់ដល់សណ្តាប់ធ្នាប់សាធារណៈ សន្តិសុខសង្គម និងបំផ្លាញសតិអារម្មណ៍របស់ប្រជាពលរដ្ឋដែលប្រើប្រាស់ ដែលច្បាប់បញ្ញត្តិឱ្យទទួលខុសត្រូវព្រហ្មទណ្ឌជាធរមាន ។

១០.ទោះបីជាជនជាប់ចោទឈ្មោះ [redacted] **ជាទីត** និងឈ្មោះ [redacted] **លីដា** បានប្រព្រឹត្តកើតឡើងក៏ពិតប្រាកដមែន ដែលតាមច្បាប់ស្តីពីយុត្តិធម៌អនីតិជន និងក្រមព្រហ្មទណ្ឌ និងសន្ធិសញ្ញាស្តីពីការការពារកុមារ គឺបានផ្តល់ ផលប្រយោជន៍ទៅឱ្យអនីតិជន លើសពីនេះទៀតក៏បានផ្តល់នូវស្ថានសម្រាលទោស ដែលជាប្រយោជន៍ទៅឱ្យអនីតិជនដោយការកាត់បន្ថយនូវពាក់កណ្តាលនៃអតិបរមា និងត្រូវបន្ថយពាក់កណ្តាលនៃអប្បបរមាលើសពី១ថ្ងៃ តាមក្រមព្រហ្មទណ្ឌ។

១១.វត្ថុតាងដែលដកហូតមាន ទូរសព្ទចំនួន ០១គ្រឿង ម៉ាក VIVO ពណ៌សលាយផ្កាឈូក មានសភាពបែកអេក្រង់ដោយកន្លែង ម៉ាស៊ីនដំណើរការ(ចាស់) ដកហូតពីឈ្មោះ [redacted] **ជាទីត** រក្សាទុកនៅលេខាធិការដ្ឋានរដ្ឋបាលសាលាដំបូងខេត្តបន្ទាយមានជ័យ **គប្បីរឹបអូស** តាមបញ្ញត្តិមាត្រា **៩៣** នៃច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន ។

## <u>ហេតុដូចនេះសម្រេច</u>

I. **ផ្តន្ទាទោសជនជាប់ចោទ ៖**

១.ឈ្មោះ [redacted] **ជាទីត** ភេទប្រុស កើតថ្ងៃទី០៨.០៩.២០០៣ សញ្ជាតិខ្មែរ អនីតិជន មុខរបរកម្មករ សាសនាគ្រិស្ត កម្រិតវប្បធម៌ថ្នាក់ទី១០ថ្មី ទីកន្លែងកំណើត [redacted] ខេត្តបន្ទាយមានជ័យ អាសយដ្ឋានមុនពេលឃុំខ្លួន [redacted] ខេត្តបន្ទាយមានជ័យ ឪពុកឈ្មោះ [redacted] ភិន (រស់) ម្តាយឈ្មោះ [redacted] សាវរ៉េត (រស់) នៅលីវ ទោសពីមុន **ធ្លាប់ជាប់មណ្ឌលកែប្រែជីវិតថ្មីភ្នំបាក់ចំនួន ០៣ ខែ។** (ក្នុងឃុំ)

(ដីកាបង្គាប់ឱ្យឃុំខ្លួនលេខ : ៦២៧ ព្រ.ទ III-ឈ-/២០ ចុះថ្ងៃទី១៣ ខែតុលា ឆ្នាំ២០២០)

**ដាក់ពន្ធនាគារកំណត់រយៈពេល ១៤ (ដប់បួន) ខែ ពីបទ "ជួញដូរ និងប្រើប្រាស់ដោយខុសច្បាប់នូវសារធាតុញៀន"** ប្រព្រឹត្តនៅភូមិភ្នំតូចត្បូង ឃុំភ្នំតូច ស្រុកមង្គលបូរី ខេត្តបន្ទាយមានជ័យ កាលពីថ្ងៃទី១០ ខែតុលា ឆ្នាំ២០២០ តាមបញ្ញត្តិមាត្រា **៤០ កថាខណ្ឌ៤** និងមាត្រា **៤៥** នៃច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន។

២.ឈ្មោះ [redacted] លីដា ភេទស្រី កើតឆ្នាំ២០០៤ សញ្ជាតិខ្មែរ អនីតិជន មុខរបរ នៅផ្ទះ សាសនាព្រះពុទ្ធ កម្រិតវប្បធម៌ថ្នាក់ទី១១ថ្មី ទីកន្លែងកំណើតភូមិ[redacted] ខេត្តបន្ទាយមានជ័យ អាសយដ្ឋានមុនពេលឃុំខ្លួន[redacted] ខេត្តបន្ទាយមានជ័យ ឪពុកឈ្មោះ [redacted] វ៉ាន់ (រស់) ម្តាយឈ្មោះ [redacted] ឆាត (រស់) នៅលីវ ទោសពីមុន **គ្មាន**។ (ក្នុងឃុំ) (ដីកាបង្គាប់ឱ្យឃុំខ្លួនលេខ : ៦២៨ ព្រ.ទIII"ឈ"/២០ ចុះថ្ងៃទី១៣ ខែតុលា ឆ្នាំ២០២០)។ (គេចខ្លួន)

**ដាក់ពន្ធនាគារកំណត់រយៈពេល ១៤ (ដប់បួន) ខែ** ពីបទ **"ជួញដូរ និងប្រើប្រាស់ដោយខុសច្បាប់នូវសារធាតុញៀន"** ប្រព្រឹត្តនៅភូមិភ្នំតូចត្បូង ឃុំភ្នំតូច ស្រុកមង្គលបូរី ខេត្តបន្ទាយមានជ័យ កាលពីថ្ងៃទី១០ ខែតុលា ឆ្នាំ២០២០ តាមបញ្ញត្តិមាត្រា **៤០ កថាខណ្ឌ៤** និងមាត្រា **៤៥** នៃច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន។

II. **វត្ថុតាងដែលដកហូតមាន** :

**១.**ស្រោមសំបុត្រ ពណ៌ស បិទជិត ចំនួន ០១ ដែលមានហត្ថលេខាឈ្មោះ [redacted] សារី , ឈ្មោះ [redacted] សុវណ្ណា និងស្នាមមេដៃឈ្មោះ [redacted] **ដារ៉ែត** (០.២១ ក្រាម) និង

២.ទូរសព្ទចំនួន ០១គ្រឿង ម៉ាក VIVO ពណ៌សលាយផ្កាឈូក មានសភាពបែកអេក្រង់ដោយកន្លែង ម៉ាស៊ីនដំណើរការ(ចាស់) ដកហូតពីឈ្មោះ [redacted] **ដារ៉ែត**

រក្សាទុកនៅលេខាធិការដ្ឋានរដ្ឋបាលសាលាដំបូងខេត្តបន្ទាយមានជ័យ **ត្រូវរឹបអូស** តាមបញ្ញត្តិមាត្រា **៩៣** នៃច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន។

III. សាលក្រមនេះជំនុំជម្រះ និងប្រកាសជាអសាធារណៈចំពោះមុខជនជាប់ចោទឈ្មោះ [redacted] **ដារ៉ែត** និងឈ្មោះ [redacted] **លីដា** ។

បើកសិទ្ធិឱ្យប្តឹងឧទ្ធរណ៍តាមកំណត់របស់ច្បាប់ ។

**ក្រឡាបញ្ជីសវនាការ** **ចៅក្រមប្រឹក្សា** **ប្រធានក្រុមប្រឹក្សាជំនុំជម្រះ**

[redacted]

**បានចម្លងត្រឹមត្រូវតាមច្បាប់ដើម**

ថ្ងៃព្រហស្បតិ៍ ៥កើត ខែចេត្រ ឆ្នាំជូត ទោស័ក ព.ស.២៥៦៤

ធ្វើនៅបន្ទាយមានជ័យ ថ្ងៃទី១៨ ខែមីនា ឆ្នាំ២០២១

**បានឃើញ**

**ប្រធានក្រុមប្រឹក្សាជំនុំជម្រះ**

[redacted]

**ក្រឡាបញ្ជីសវនាការ**

[redacted]



Scanned with CamScanner